ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ

Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Dec-2017, 12:13
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

លេខ: ០០៤/១/០៧-០៩-២០០៩/អវតក/កសចស(អបជ៥០)

**សាធារណៈ**

**ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧**

**ម៉ោង ០៩: ៤៦នាទី**

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន (ប្រធានអង្គបុរេ)

ចៅក្រម អូលីវីយេ បូវ៉ាល្លេត៍
*(Judge Olivier BEAUVALLET)*

ចៅក្រម ន័យ ថុល

ចៅក្រម កាំង ជីន បាក់
*(Judge Kang Jin BAIK)*

ចៅក្រម ហួត វុទ្ធី

**ក្រឡាបញ្ជី៖**

លោកស្រី រស់ បូផាណា

លោកស្រី អែលសា ឡេវ៉ាវ៉ាស័រ
*(Mr. Elsa LEVAVASSEUR)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicholas KOUMJIAN)*

លោក សេង ប៊ុនឃាង

លោក កូមេន ខេននី *(Mr. Coman KENNY)*

**ជនត្រូវចោទ៖**

លោកស្រី អ៊ឹម ចែម

**មេធាវីការពារជនត្រូវចោទ៖**

លោក ប៊ិត ស៊ាងលឹម

លោក វ៉ាន ហ្សកដាហ្ស *(Mr.Wayne JORDASH)*

កញ្ញា ហ្សូល្យាន រូមី *(Ms. Julianne ROMY)*

កញ្ញា អាស្ត្រីដ ប៉ុងស៊ុលេ
*(Ms. Astrid PONSOLLE)*

លោក លៀម ម៉ាក អានឌ្រូ
*(Mr. Liam MacAndrews)*

លោកស្រី វី ណូយែល

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក សំ សុគង់

លោកស្រី លីម៉ា ង្វៀន *(Lyma NGUYEN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ប្រាក់ គឹមសាន (ប្រធានអង្គបុរេ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:៤៦:១៥]

**ក្រឡាបញ្ជី៖**

...ម៉ាស៊ីនថតវីដេអូ ឧបករណ៍ថតសំឡេង និងឧបករណ៍បំពងសំឡេងគ្រប់ប្រភេទចូលក្នុងសាលសវនាការ លើកលែងតែមានការអនុញ្ញាតពីអង្គបុរេជំនុំជម្រះ។ ៣) ហាមជក់បារី ឬយកចំណីអាហារ ភេសជ្ជៈគ្រប់ប្រភេទចូលក្នុងសាលសវនាការ។ ៤) ហាមយកអាវុធគ្រប់ប្រភេទចូលក្នុងសាលសវនាការ លើកលែងតែភ្នាក់ងារសន្តិសុខដែលមានសមត្ថកិច្ច។ ៥) ហាមប្រើប្រាស់ទូរស័ព្ទគ្រប់ប្រភេទក្នុងសាលសវនាការ ហាមថតរូបភាព ឬសំឡេងតាមគ្រប់មធ្យោបាយ។ ៦) ហាមប្តូរកន្លែងអង្គុយ ឬដើររហេតរហូតក្នុងសាលសវនាការ។ ៧) ហាមទះដៃ ឬស្រែកជយឃោស ឬស្រែកឡូឡា ឬការធ្វើឱ្យមានសំឡេងខ្លាំង នាំឱ្យរំខានដល់ដំណើរការសវនាការ។ ៨) ហាមដើរចេញចូលដោយអាណាធិបតេយ្យនៅពេលសវនាការ។ ការចេញចូលត្រូវមានការអនុញ្ញាតពីកម្លាំងសន្តិសុខរក្សាសណ្តាប់ធ្នាប់ក្នុងសាលសវនាការ។ ៩) ក្នុងករណីមានបុគ្គលប្រព្រឹត្តបទល្មើសនឹងបទបញ្ជាផ្ទៃក្នុង ប្រធានអង្គបុរេជំនុំជម្រះនឹងចាត់វិធានការដើម្បីរារាំង ឬទប់ស្កាត់ភ្លាមតាមករណីសមស្រប ផ្អែកតាមវិធានផ្ទៃក្នុងនៃអង្គបុរេជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

*(សម្រាករយៈពេលខ្លី)*

តុលាការ!

[០៩:៤៩:០៥]

**ប្រធានអង្គបុរេ៖**

សូមចាប់ផ្តើមធ្វើការបាទ!

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ ថ្ងៃនេះអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើកសវនាការដើម្បីស្តាប់អំណះអំណាងរបស់ភាគី មុននឹងចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបសួរ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧។

អ្នកចូលរួមនៅក្នុងសវនាការមានដូចតទៅ៖ សហមេធាវីការពារក្តីឱ្យជនត្រូវចោទ លោក ប៊ិត សេងលីម, លោក វ៉ាន់ ហ្សកដាហ្ស, ហ្ស៊ីល្យាន រូមី, លោកស្រី អាស្ត្រីដ ប៉ុងសូល, លោក យាម ម៉ាក

អេនគ្រូ និងលោកស្រី ណូយ៉ែល រី។ សហមេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណី លោក សំ សុគង់ និង លីម៉ា ង្វៀន បាទលោកស្រី លីម៉ា ង្វៀន។

ក្រឡាបញ្ជី តើភាគីមានវត្តមានគ្រប់ចំនួនហើយឬនៅ?

បូវ៉ាល្តេត៍ ជាថៅក្រម, លោក ន័យ ថុល ជាថៅក្រម, លោក កាំង ជីន បាក់ ជាថៅក្រម លោក ហួត វុទ្ធី ជាថៅក្រម។ ក្រឡាបញ្ជីមានលោកស្រី រស់ បូផាណា, កញ្ញា អែលសា ឡឺវ៉ាវ៉ាស័រ។ សហព្រះរាជអាជ្ញា មានលោក សេង ប៊ុនឃាង ព្រះរាជអាជ្ញាជាតិ, លោក នីកូឡាស គូមជែន សហព្រះរាជអាជ្ញាអន្តរជាតិ។

តទៅនេះខ្ញុំសូមប្រកាសបិទសវនាការជាសាធារណៈ!

ដូច្នេះ សូមអ្នកស្តាប់សវនាការអញ្ជើញចេញពីសាលសវនាការ!

*(សវនាការសាធារណៈផ្អាកនៅម៉ោង ០៩:៥៤ នាទី)*